អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

**ថ្ងៃទី៥ ខែឧសភា ឆ្នាំ២០០៩**

# សេចក្តីប្រកាសព័ត៌មាន

## អង្គបុរេជំនុំជម្រះបដិសេធបណ្តឹងឧទ្ធរណ៍របស់ នួន ជា ប្រឆាំងនឹងការបន្តថេរវេលា នៃការឃុំខ្លួនបណ្តោះអាសន្ន

នៅក្នុងសាលដីកានាថ្ងៃទី៤ ខែឧសភា ឆ្នាំ២០០៩ អង្គបុរេជំនុំជម្រះបដិសេធបណ្តឹងឧទ្ធរណ៍របស់ នួន ជា ប្រឆាំងនឹងដីកាសម្រេចអំពីការបន្តថេរវេលានៃការឃុំខ្លួនបណ្តោះអាសន្ន និងបដិសេធសំណើសុំដោះលែងដោយមានលក្ខខណ្ឌ។ អនុលោមតាមសាលដីការបស់អង្គបុរេជំនុំជម្រះ នួន ជា អាចត្រូវស្ថិតក្នុងការឃុំខ្លួនបណ្តោះអាសន្នរហូតដល់ថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០០៩។

នួន ជា ដែលបានកាន់តួនាទីជាអនុលេខាបក្ស និងជាសមាជិកនៃគណៈអចិន្ត្រៃយ៍បក្សកុម្មុយនីស្តកម្ពុជា ត្រូវបានចោទប្រកាន់ពីបទឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ និងការបំពារបំពានយ៉ាងធ្ងន់ធ្ងរលើសន្ធិសញ្ញាទីក្រុងហ្សឺណែវឆ្នាំ១៩៤៩ (សំណុំរឿងនេះគឺកំពុងស្ថិតនៅក្រោមការស៊ើបអង្កេត)។ នួន ជា ត្រូវបានសហចៅក្រមស៊ើបអង្កេតចេញដីកាឃុំខ្លួនបណ្តោះអាសន្នជាលើកដំបូងរយៈពេលមួយឆ្នាំកាលពីថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០០៧។ កាលពីថ្ងៃទី ១៦ ខែកញ្ញា ឆ្នាំ២០០៨ សហចៅក្រមស៊ើបអង្កេតបានចេញដីកាបន្តថេរវេលានៃការឃុំខ្លួនបណ្តោះអាសន្នរយៈពេលជាអតិបរមាចំនួនមួយឆ្នាំទៀត (រហូតដល់ថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០០៩)។

នៅក្នុងបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចការបន្តថេរវេលានៃការឃុំខ្លួនបណ្តោះអាសន្ន សហមេធាវីការពារក្តីឲ្យ នួន ជា បានសន្និដ្ឋានថាការបន្តថេរវេលាឃុំខ្លួនគឺមិនមានយុត្តិកម្មទាំងអង្គហេតុទាំងអង្គច្បាប់ ហើយបានស្នើសុំឲ្យដោះលែង នួន ជា បណ្តោះអាសន្នដោយមានលក្ខខណ្ឌ។

នៅក្នុងសាលដីកាបដិសេធបណ្តឹងឧទ្ធរណ៍ អង្គបុរេជំនុំជម្រះបានយល់ឃើញថាវិធានការនៃការបន្តថេរវេលានៃការឃុំខ្លួនបណ្តោះអាសន្ននៅតែជាវិធានការចាំបាច់ដើម្បីរារាំងជនត្រូវចោទមិនឲ្យដាក់ការគាបសង្កត់ទៅលើសាក្សី ឬបំផ្លាញភស្តុតាង។ លើសពីនេះទៅទៀត គឺដើម្បីធានាឲ្យមានវត្តមានរបស់ជនត្រូវចោទក្នុងដំណើរការនីតិវិធី ដើម្បីការពារសន្តិសុខរបស់ជនត្រូវចោទ និងរក្សាសណ្តាប់ធ្នាប់សាធារណៈ។

សាលដីការបស់អង្គបុរេជំនុំជម្រះអាចស្វែងរកបានក្នុងគេហទំព័រ៖
http://www.eccc.gov.kh/khmer/cabinet/courtDoc/274/C9_4_6_KH.pdf

សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទង


លោក ឡាស អូលសិន
មន្ត្រីទទួលបន្ទុកទំនាក់ទំនងផ្លូវច្បាប់
ទូរស័ព្ទចល័ត: +855 (0) 12 488 023
ទូរស័ព្ទ: +855 (0) 23 219 814 លេខបន្ត 6169
សារអេឡិចត្រូនិច: olsenl@un.org

បណ្ឌិត ហេឡិន ចារវីស
ប្រធានផ្នែកកិច្ចការសាធារណៈ
ទូរស័ព្ទចល័ត: +855-12 488 134
ទូរសារ: +855-23 219 841
សារអេឡិចត្រូនិច: helen.jarvis@eccc.gov.kh

លោក រាជ សម្បត្តិ
មន្ត្រីទទួលបន្ទុកផ្នែកព័ត៌មាន
ទូរស័ព្ទចល័ត: +855-12 488 156
ទូរសារ: +855-23 219 841
សារអេឡិចត្រូនិច: reach.sambath@eccc.gov.kh